**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ៖ **២០៨ អក**

ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២

សាលក្រមព្រហ្មទណ្ឌលេខ៖ **១០០ "ខ"**

ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២

# សាលក្រមព្រហ្មទណ្ឌ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ០២ និង ៣០នាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

### មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោក [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **វ័ន**

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ **២០៨ អក** ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] **វ័ន** ភេទប្រុស អាយុ ៣៥ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិខ្មែរ មុខរបរ អ្នកបើកឡាន មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] វី(រស់) ម្តាយឈ្មោះ [redacted] ស្រីតា (រស់) ប្រពន្ធឈ្មោះ [redacted] តនា (រស់) មានកូន ០២នាក់ កម្រិតវប្បធម៌ ថ្នាក់ទី៧ ជានីតិជន ទោសពីមុនគ្មាន ។ **(ឃុំខ្លួនថ្ងៃទី០៨.០២.២២)**

ជាប់ចោទពីបទ៖ **ប៉ុនប៉ងឃាតកម្ម និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកតាកែវ២ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា**២៧** និងមាត្រា**១៩៩** នៃក្រមព្រហ្មទណ្ឌ និងមាត្រា**៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។

-**បានឃើញ** របាយការណ៍សរុបលេខ៖ ០៨៦ របក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ។



Scanned with CamScanner

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ របស់ឈ្មោះ [redacted] វាសនា។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៖ ១៥១ ដកសស ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ៦៨២ ដកសព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ៖ ៧២១ ដកដស ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះលេខ៖ ៧៤២ ដកចត/២២ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ:-

នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង០៧ និង ៣០ នាទី ស្ថិតនៅភូមិព្រែកតាកែវ២ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] វ៉ន ភេទប្រុស អាយុ ៣៥ឆ្នាំ បានបើកបររថយន្តមួយគ្រឿង មកចតនៅមុខតូបជួសជុលម៉ូតូរបស់ឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ ៣៤ឆ្នាំ ដែលត្រូវជាប្អូនថ្លៃ ហើយខណៈពេលនោះជនជាប់ចោទឈ្មោះ [redacted] វ៉ន និងឈ្មោះ [redacted] វាសនា ក៏បានទាស់សម្តីគ្នាពីរឿងជួលមេន ដោយមានការខឹងនឹងឈ្មោះ [redacted] វាសនា ភ្លាមនោះជនជាប់ចោទឈ្មោះ [redacted] វ៉ន បានស្ទុះទៅទាញយកពូថៅពីក្រោមកៅអីរថយន្តរបស់ខ្លួន ស្ទុះទៅកាប់លើឈ្មោះ [redacted] វាសនា ត្រូវមួយពូថៅចំក្បាល បណ្តាលឱ្យរងរបួសស្នាមជាទម្ងន់ ពេលនោះជនរងគ្រោះបានរត់គេចពីជនជាប់ចោទ និងស្រែកឱ្យគេជួយ ហើយក៏បានអ្នកជិតខាងចូលមកជួយឃាត់ទៅ ។ បន្ទាប់មកជនរងគ្រោះក៏បានប្តឹងសមត្ថកិច្ចនគរបាល ចុះមកចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] វ៉ន បានភ្លាមៗ និងចាប់យកវត្ថុតាង(ពូថៅ) ហើយនាំខ្លួនជនជាប់ចោទ យកទៅកសាងសំណុំរឿងបញ្ជូនជនជាប់ចោទរួមនឹងវត្ថុតាងមកអយ្យការអមសាលាដំបូងខេត្តកណ្តាល ដើម្បីចាត់ការតាមច្បាប់។

## នាពេលសវនាការ

១- ជនជាប់ចោទឈ្មោះ [redacted] វ៉ន បានឆ្លើយថា៖ ខ្ញុំទទួលស្គាល់ថា ខ្ញុំពិតជាបានកាប់ប្អូនថ្លៃប្រាកដមែន តែមិនមានបំណងសម្លាប់វាទេ ។ ខ្ញុំកាប់តែមួយពូថៅ ចំគុម្ពត្រចៀក ឈាមតែបន្តិច មុនដំបូងវាដើរចូលមករកវាយខ្ញុំ ទើបខ្ញុំកាប់តែម្តង ។ ខ្ញុំធ្លាប់មានរឿងជួលមេន ពីមុនមកធ្លាប់មានរឿងបន្តិចបន្តួច តែមិនដែលមានហិង្សាទេ ។ ខ្ញុំធ្លាប់ប្រើប្រាស់ថ្នាំញៀនប្រហែល ០២ឆ្នាំ មកហើយ ។ ឈ្មោះ [redacted] វាសនា ត្រូវជាប្អូនថ្លៃ ថ្ងៃនោះខ្ញុំបើកឡានកូរ៉េ មួយគោនកន្លះ ពូថៅទុកលើឡាន ទាស់គ្នានៅកន្លែងធ្វើការ ។ កាប់ចំគុម្ពត្រចៀក ។ ពូថៅសម្រាប់សម្រាប់ធ្វើការ កាប់មិនមែនឱ្យស្លាប់ទេ ។

២- តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វាសនា នៅដំណាក់កាលនគរបាលយុត្តិធម៌ បានឆ្លើយថា៖ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ០៦ និង ៤០ នាទីព្រឹក ខ្លួននៅរោងប៉ះកង់នៅជាប់

ផ្លូវជាតិលេខ ១ ខ្លួនអង្គុយចាំឡានមកដឹកមេនទៅដំឡើងឱ្យបុណ្យសពគេនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ប៉ុន្តែមិនទាន់បានដឹកទៅតំឡើងមេនបុណ្យសពឱ្យគេទេ ស្រាប់តែឈ្មោះ [redacted] វ័ន ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ មានទីលំនៅភូមិព្រែកតាកែវ២ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល (ត្រូវជាបងថ្លៃ) ក៏បានបើកឡានមកដល់កន្លែងរោងប៉ះកង់របស់ខ្លួន រួចហើយខ្លួនក៏បានដើរចេញពីរោងប៉ះកង់ទៅឡើងឡាន តម្លើងមេនបុណ្យសពឱ្យគេនៅភូមិជ័យឧត្តម ប៉ុន្តែខ្លួនឈានជើងឡើងមិនទាន់ផុតផងស្រាប់តែឈ្មោះ [redacted] វ័ន ភេទប្រុស (ត្រូវជាបងថ្លៃ) បានយកពូថៅមកកាប់ចំក្បាលចំហៀងខាងឆ្វេងបណ្ដាលឱ្យមានរបួសហូរឈាម និងបានដេរអស់ចំនួនប្រាំថ្នេរ ។ នៅថ្ងៃ ខែ មិនចាំក្នុងឆ្នាំ ២០២១ ខ្លួនបានធ្លាប់ឈ្លោះប្រកែកជាមួយបងថ្លៃម្ដងមកហើយ ។

៣- តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ ជនជាប់ចោទបានឆ្លើយសារភាពហើយថា ដោយសារមានទំនាស់គុំគួន ពេលជួបគ្នា ទាស់សំដីគ្នា យកពូថៅដែលទុកក្នុងរថយន្តកាប់ជនរងគ្រោះតែម្ដង កាប់សំដៅក្បាលបំណងផ្ដាច់ជីវិតតែម្ដង ។ ដូច្នេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំតុលាការសម្រេចតាមច្បាប់។

៤- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីខ្ញុំបាទធ្វើខុសមួយពេលដោយកាប់លើជនរងគ្រោះ ក្រោយពេលឃុំខ្លួនដឹងកំហុស និងកែប្រែខ្លួន សុំតុលាការមេត្តាបន្ធូបន្ថយទោស ដើម្បីឆាប់បានចេញពីពន្ធនាគារ ក្លាយជាពលរដ្ឋល្អ ។

៥- សម្ដីចុងក្រោយរបស់ជនជាប់ចោទ៖ សុំតុលាការមេត្តាបន្ធូបន្ថយឲ្យខ្ញុំបាទផង ។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកណ្ដាល

## យល់ឃើញថា

១- នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង០៧ និង ៣០ នាទី ស្ថិតនៅភូមិព្រែកតាកែវ២ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ជនជាប់ចោទឈ្មោះ [redacted] វ័ន ភេទប្រុស អាយុ ៣៥ឆ្នាំ បានបើកបររថយន្តមួយគ្រឿង មកចតនៅមុខតូបជួសជុលម៉ូតូរបស់ឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ ៣៤ឆ្នាំ ដែលត្រូវជាប្អូនថ្លៃ ហើយខណៈពេលនោះជនជាប់ចោទឈ្មោះ [redacted] វ័ន និងឈ្មោះ [redacted] វាសនា ក៏បានទាស់សម្ដីគ្នាពីរឿងជួលមេន

ដោយមានការខឹងនឹងឈ្មោះ [redacted] វាសនា ភ្លាមនោះជនជាប់ចោទឈ្មោះ [redacted] វ័ន បានស្ទុះទៅទាញយកពូថៅពីក្រោមកៅអីរថយន្តរបស់ខ្លួន ស្ទុះទៅកាប់លើឈ្មោះ [redacted] វាសនា ត្រូវមួយពូថៅចំក្បាល បណ្តាលឱ្យរងរបួសស្នាមជាទម្ងន់ ពេលនោះជនរងគ្រោះបានរត់គេចពីជនជាប់ចោទ និងស្រែកឱ្យគេជួយ ហើយក៏បានអ្នកជិតខាងចូលមកជួយឃាត់ទៅ ។ បន្ទាប់មកជនរងគ្រោះក៏បានប្ដឹងសមត្ថកិច្ចនគរបាល ចុះមកចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] វ័ន បានភ្លាមៗ និងចាប់យកវត្ថុតាង(ពូថៅ) ហើយនាំខ្លួនជនជាប់ចោទ យកទៅកសាងសំណុំរឿងបញ្ជូនជនជាប់ចោទរួមនឹងវត្ថុតាងមកអយ្យការអមសាលាដំបូងខេត្តកណ្តាល ដើម្បីចាត់ការតាមច្បាប់។

២- ជនជាប់ចោទឈ្មោះ [redacted] វ័ន ជានីតិជនមានសមត្ថភាព និងមានលក្ខណៈសម្បត្តិល្អគ្រប់គ្រាន់ដែលអាចដឹង និងទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួនបាន ។

៣- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វ័ន ដែលបានឆ្លើយថា៖ ខ្លួនទទួលស្គាល់ថា ខ្លួនពិតជាបានកាប់ប្អូនថ្លៃប្រាកដមែន តែមិនមានបំណងសម្លាប់វាទេ ។ ខ្លួនកាប់តែមួយពូថៅ ចំគុម្ពត្រចៀក ឈាមតែបន្តិចមុនដំបូងវាដើរចូលមករកវាខ្លួន ទើបខ្លួនកាប់តែម្តង ។ ខ្លួនធ្លាប់មានរឿងជួលមេន ពីមុនមកធ្លាប់មានរឿងបន្តិចបន្តួច តែមិនដែលមានហិង្សាទេ ។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនប្រហែល ០២ឆ្នាំ មកហើយ ។ ឈ្មោះ [redacted] វាសនា ត្រូវជាប្អូនថ្លៃ ថ្ងៃនោះខ្លួនបើកឡានកូរ៉េ មួយគោនកន្លះ ពូថៅទុកលើឡាន ទាស់គ្នានៅកន្លែងធ្វើការ ។ កាប់ចំគុម្ពត្រចៀក ។ ពូថៅសម្រាប់សម្រាប់ធ្វើការ កាប់មិនមែនឱ្យស្លាប់ទេ ចម្លើយនេះអាចឱ្យតុលាការជឿបានថា ជនជាប់ចោទរូបនេះ ពិតជាពុំមានចេតនាសម្លាប់ជនរងគ្រោះប្រាកដមែន ដោយហេតុ បើជនជាប់ចោទមានចេតនាសម្លាប់ជនរងគ្រោះ នោះជនជាប់ចោទមិនមែនកាប់ជនរងគ្រោះតែមួយពូថៅហើយឈប់នោះទេ គឺនឹងកាប់បន្ថែមទៀតហើយ ។ម្យ៉ាងវិញទៀតព្យសនកម្មដែលបង្កឡើងដោយជនជាប់ចោទរូបនេះ(របួសជនរងគ្រោះ) ក៏មានលក្ខណៈតិចតួច មិនបង្កឱ្យប៉ះពាល់ដល់អាយុជីវិតរបស់ជនរងគ្រោះនោះទេ ដូច្នេះតុលាការគប្បីកែប្រែបទចោទប្រកាន់លើជនជាប់ចោទរូបនេះ ពីបទ៖ **ប៉ុនប៉ងឃាតកម្ម** តាមបញ្ញត្តិមាត្រា **២៧** និងមាត្រា **១៩៩** នៃក្រមព្រហ្មទណ្ឌ មកជាបទ៖ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ វិញ ។

៤- តាមចម្លើយសារភាពរបស់ជនជាប់ចោទ , អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ធៀបនឹងឯកសារភស្តុតាងគតិយុត្តិនានាដែលមាននៅក្នុងសំណុំរឿងឃើញថា នៅថ្ងៃកើតហេតុជនជាប់ចោទឈ្មោះ [redacted] វ័ន ពិតជាបានកាប់ជនរងគ្រោះបណ្តាលឱ្យរងរបួសចេញឈាមប្រាកដមែន ។

៥- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វ័ន ភេទប្រុស អាយុ ៣៥ឆ្នាំ ពីបទ៖**ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកតាកែវ ២ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ និងមាត្រា**៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។



Scanned with CamScanner

៦- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វាសនា ពុំបានចូលមកឆ្លើយនៅដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ដើម្បីទាមទារថ្លៃព្យាបាល និងសំណងជម្ងឺចិត្តអ្វីពីជនជាប់ចោទឈ្មោះ [redacted] វ៉ន ទេ ដូច្នេះតុលាការពុំមានមូលដ្ឋានក្នុងសម្រេចសេចក្ដីលើបញ្ហានេះឡើយ តែតុលាការទុកសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីទាមទារសំណងផ្សេងៗនៅពេលក្រោយបាន ។

៧- **វត្ថុតាងចាប់យករួមមាន៖** ពូថៅដងឈើចំនួន ០១ គប្បីតុលាការសម្រេចរឹបអូស ។

**ហេតុដូច្នេះសម្រេច**

១- កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] វ៉ន ភេទប្រុស អាយុ ៣៥ឆ្នាំ ពីបទ៖ **ប៉ុនប៉ងឃាតកម្ម** តាមបញ្ញត្តិមាត្រា **២៧** និងមាត្រា **១៩៩** នៃក្រមព្រហ្មទណ្ឌ មកជាបទ៖ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ វិញ ។

២-**ផ្ដន្ទាទោសជនជាប់ចោទ** ឈ្មោះ [redacted] វ៉ន ភេទប្រុស អាយុ ៣៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤ (បួន) ឆ្នាំ ។

ពីបទ៖ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកតាកែវ២ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ **នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន**។

៣-**វត្ថុតាងដែលបានចាប់យករួមមាន៖** ពូថៅដងឈើចំនួន ០១ សម្រេចរឹបអូស ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វ៉ន និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វាសនា ។

*ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។*

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

កណ្ដាល. ថ្ងៃទី.22..ខែ.[illegible]....ឆ្នាំ 2022

**ក្រឡាបញ្ជី**

[redacted]

**មន្ត្រីលេខា និងត្រា**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ក្រឡាបញ្ជីសវនាការ

---

**បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម ។**

ថ្ងៃពុធ ១២កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្ដាល ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ក្រឡាបញ្ជី**

[redacted]

[redacted]